## ខ្លឹមសារសង្ខេប

## សេចក្តីសម្រេច ស្តីពី សាទុក្ខ ប្រឆាំងនឹង ការបដិសេធ ញត្តិជំទាស់បឋម (Preliminary Objection) ផ្អែកលើការលើកលែងទោស

១. លោក **អៀង សារី** ត្រូវបានព្រះមហាក្សត្រលើកលែងទោស ក្នុងឆ្នាំ ១៩៩៦ មុនពេលគាត់ត្រូវបានចាប់ខ្លួនឃុំនៅក្នុង អវតក។ ក្នុងដំណើរការជាហូរហែ គាត់បានលើកអំពី ការលើកលែងទោសនេះជារបាំង មិនឲ្យមានការឃុំខ្លួន ចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះ។ ក្នុងញត្តិជំទាស់ដំបូង គាត់បានលើករឿងនេះ នៅមុខអង្គជំនុំជម្រះសាលាដំបូង។ សាលាដំបូង បានបដិសេធ ដោយអះអាងនូវចំណុចជាច្រើន ដូចជាបទល្មើសដែលទទួលបានការលើកលែងទោសពីព្រះមហាក្សត្រ ខុសពីបទល្មើសដែលត្រូវបានចោទដោយ អវតក ហើយយុត្តិសាស្ត្រតុលាការអន្តរជាតិ មិនឲ្យជនល្មើសរួចផុតពីការទទួលខុសត្រូវបទឧក្រិដ្ឋកម្មអន្តរជាតិ ដូចជា បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ (Crime against Humanity) ឡើយ។ [1]

២. ការលើកលែងទោស ជារបាំងមិនឲ្យមានការកាត់ទោស ដែលអាចនាំឲ្យបញ្ចប់នីតិវិធី ជាកម្មវត្ថុនៃការប្តឹងតាមវិធាន ១០៤(៤.ក) (appeal against decisions that have the effect of terminating the proceedings) ហើយសហព្រះរាជអាជ្ញាអាចប្តឹងសាទុក្ខបាន។ ក្នុងករណីនេះ សាលាដំបូង បានសម្រេចមកខាងសហព្រះរាជអាជ្ញា(មិនជារបាំង)។ លោក **អៀង សារី** បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាដំបូងក្នុងរឿងនេះ ដើម្បីជំទាស់យុត្តាធិការ អវតក ផ្អែកលើការលើកលែងទោស ឆ្នាំ១៩៩៦, អាជ្ញាអស់ជំនុំ (*res judicata*) ក្រោមច្បាប់កម្ពុជា និង ការហាមឃាត់ការកាត់សេចក្តីពីរដង (*ne bis in idem*) តាមមាត្រា ១៤(៧) នៃកតិកាសញ្ញា ស្តីពីសិទ្ធិប្រជាពលរដ្ឋ(ទំ.២)។ បន្ថែមលើនេះ លោក **អៀង សារី** ថ្លែងថាបើសាលាដំបូងសម្រេចឲ្យសហព្រះរាជអាជ្ញាចាញ់ សហព្រះរាជអាជ្ញានឹងប្តឹងសាទុក្ខ។ តាមទ្រឹស្តីសមភាពនៃភាគី (equality of arms) គាត់ (**អៀង សារី**) ក៏អាចប្តឹងសាទុក្ខបានដូចគ្នា។

៣. តុលាការកំពូលផ្តល់សំអាងហេតុថា៖ **ទី១**. មិនមានសិទ្ធិទូទៅប្តឹងសារទុក្ខ (interlocutory appeal) **ទី២**. តាមយុត្តិសាស្ត្ររបស់ អវតក វិធាន ១០៤(៤.ក) អនុញ្ញាតសាទុក្ខ ប្រឆាំងនឹងសេចក្តីសម្រេច ដែលនាំឲ្យបញ្ចប់នីតិវិធីតែប៉ុណ្ណោះ និង លោក **អៀង សារី** នៅតែអាចធ្វើសាទុក្ខក្នុងបញ្ហានេះជាផ្នែកមួយ នៃសាទុក្ខប្រឆាំងនឹងសាលក្រមរបស់សាលាដំបូងនាពេលខាងមុខ។ ការបកស្រាយវិធាន

---

[1] ECCC Trial Chamber, Case 002, Decision on IENG Sary's Rule 89 Preliminary Objections, E51/15, 2 November 2011 (Public).

១០៤(៤.ក) នេះមិនប៉ះដល់គោលការណ៍សមភាពនៃភាគីទេ។ ផ្អែកលើមូលដ្ឋានទាំងនេះ តុលាការកំពូលក្នុងសំលេង ៥ ទល់ នឹង ២ សម្រេចបដិសេធបណ្តឹងសាទុក្ខនេះ (ទំ.២និង៣)។

<u>**កំណត់សំគាល់**</u>៖ **១**. សមភាពនៃភាគី ត្រូវបានលើកឡើងជាច្រើនដងក្នុងសេចក្តីសម្រេចនេះ។ តុលាការកំពូល ថ្លែងថាមិនខុសគោលការណ៍នេះទេ ពីព្រោះ លោក **អៀង សារី** នៅមានឱកាសដូចគ្នានឹងសហព្រះរាជអាជ្ញា ក្នុងការលើកបញ្ហាដដែលនេះនៅពេលក្រោយ។ **២**. សេចក្តីសម្រេចនេះ ខ្លីតែខ្លឹម មានបង្កប់នូវអំណះអំណាងផ្លូវច្បាប់ ដែលមេធាវី ថៅក្រមកម្ពុជា អាចដកស្រង់ មកសរសេរក្នុងឯកសាររបស់ខ្លួន។ **៣**. តុលាការកំពូលបានយោងដល់យុត្តិសាស្ត្ររបស់ខ្លួនផងដែរ។ សូមមើលខ្លឹមសារសង្ខេប សេចក្តីសម្រេចរបស់ សាលាដំបូងលើបញ្ហានេះបន្ថែមទៀត។

ECCC Supreme Court Chamber, Case 002, Decision on IENG Sary’s Appeal against Trial Chamber ‘s Decision on IENG Sary’s Rule 89 Preliminary Objections ), *Ne Bis In Idem* and Amnesty and Pardon, E15/15/1/2, 20 March 2012 (Public).